# តើអ្នកជឿលើព្រះយេស៊ូវ ត្រូវគោរពឪពុកម្តាយខ្លួនឬទេ?



## តើអ្នកជឿលើព្រះយេស៊ូវ ត្រូវគោរពឪពុកម្តាយខ្លួនឬទេ?

នេះគឺជាសំណួរមួយដ៏សំខាន់ណាស់ ដែលប្រជាជនខ្មែរភាគច្រើនតែងតែសួរទៅកាន់អ្នកជឿលើព្រះយេស៊ូវ ។ សំណួរនេះល្អ ពីព្រោះជនជាតិខ្មែរតាំងពីតូចមកគេទទួលការបង្រៀនថា គេគួរតែគោរពឪពុកម្តាយរបស់ខ្លួន ។ អ្នកកាន់សាសនាតែងតែធ្វើបុណ្យផ្សេងៗជូនដល់ឪពុកម្តាយរបស់ខ្លួនមុន និង ក្រោយពេលគាត់ស្លាប់ ។ ពួកគេធ្វើបុណ្យទាំងនេះ ដើម្បីសំដែងការគោរពជូនចំពោះឪពុកម្តាយរបស់គេ ។ ម្យ៉ាងវិញទៀត បុណ្យនេះនឹងជួយគាត់ក្រោយពេលគាត់ស្លាប់ទៅ ។ តាមសាសនា បុណ្យដែលគេធ្វើនោះ នឹងជួយអ្នកណាដែលធ្វើបុណ្យនោះ ឱ្យមានសេចក្តីសុខ សេចក្តីចំរើន នៅក្នុងជីវិតនេះផង និង ជាតិក្រោយផង ។

អ្នកជឿលើព្រះយេស៊ូវក៏យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការគោរពឪពុកម្តាយរបស់ខ្លួនផងដែរ ។ អ្នកជឿពិតមានសេចក្តីប្រាថ្នាដើរតាមព្រះបន្ទូលរបស់ព្រះ ។ ព្រះគម្ពីរបានបង្រៀនច្បាស់លាស់ថា អស់អ្នកណាដែលបានទទួលសេចក្តីសង្គ្រោះពីព្រះយេស៊ូវ ទ្រង់នឹងប្រទានចិត្តថ្មីឱ្យអ្នកនោះ ហើយគាត់នឹងមានសេចក្តីប្រាថ្នាធ្វើតាមគ្រប់ទាំងក្រិត្យវិន័យរបស់ព្រះអង្គ ។ មានក្រិត្យវិន័យដ៏សំខាន់មួយដែលថា :

ចូរឱ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយ ដើម្បីឱ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានឱ្យ ។ (និក្ខមនំ ២០:១២)

ព្រះយេស៊ូវមានព្រះនាមពិសេសមួយគឺ ព្រះយេហូវ៉ា ដែលមានន័យថា ព្រះដ៏ជាព្រះ ទ្រង់បានបង្កើតអ្វីៗទាំងអស់ ។ ព្រះអង្គបានប្រទានក្រិត្យវិន័យអំពីការគោរពឪពុកម្ដាយនេះដល់មនុស្សដែលជឿលើព្រះអង្គ កាលពីជាង៣៥០០ឆ្នាំមុន ។ ១៥០០ឆ្នាំក្រោយមក បន្ទាប់ពីព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ ទ្រង់បានរំលឹកកូនរបស់ទ្រង់អំពីក្រិត្យវិន័យដ៏សំខាន់នេះ ពីរដងទៀតតាមរយៈមនុស្សបរិសុទ្ធរបស់ព្រះ :

ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ដ្បិតធ្វើដូច្នោះទើបបានត្រូវ ។ ចូរគោរពប្រតិបត្តិដល់មាតាបិតាខ្លួន នេះជាបញ្ញត្តមុនដំបូងដែលជាប់មានទាំងសេចក្ដីសន្យាផង ដើម្បីឱ្យឯងរាល់គ្នាបានសេចក្ដីសុខហើយរស់នៅផែនដីជាយូរអង្វែងទៅ ។ (អេភេសូរ ៦:១-៣)

ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់ឪពុកម្ដាយក្នុងគ្រប់ការទាំងអស់ ដ្បិតព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យយ៉ាងដូច្នោះឯង ។ (កូល៉ុស ៣:២០)

ក្រិត្យវិន័យអំពីការគោរពឪពុកម្ដាយសំខាន់ណាស់ចំពោះព្រះ ។ ហេតុអ្វី? ពីព្រោះព្រះដែលបានបង្កើតយើងមក ទ្រង់ក៏បានតែងតាំងឪពុកម្ដាយយើង ធ្វើជាអ្នកគ្រប់គ្រងលើកូនរបស់គាត់ដែរ ។ កាលណាកូនមិនស្ដាប់បង្គាប់ ឬមិនគោរពឪពុកម្ដាយរបស់ខ្លួន នោះមានន័យថា កូនក៏មិនស្ដាប់បង្គាប់ និងមិនគោរពដល់ព្រះយេស៊ូវដែរ ។ អ្នកដែលមានគុណជាងគេគឺ ព្រះយេស៊ូវ ។ យើងត្រូវគោរពព្រះអង្គមុនគេបង្អស់ ។ យើងគោរពឪពុកម្ដាយយ៉ាងណានោះ យើងក៏ត្រូវគោរពដល់ព្រះដែលបង្កើតយើងយ៉ាងនោះដែរ ។

វាជាការសំខាន់ណាស់ដែលយើងយល់ថា អ្នកជឿលើព្រះយេស៊ូវត្រូវគោរពឪពុកម្ដាយរបស់ខ្លួន នៅពេលលោកទាំងពីរនៅរស់ ។ អ្នកខ្លះគោរពឪពុកម្ដាយរបស់ខ្លួនក្រោយពេលគាត់ស្លាប់ ប៉ុន្តែពេលគាត់នៅរស់ កូនបែរជាមិនស្ដាប់បង្គាប់ និង មិនគោរពគាត់ទៅវិញ ។ ពេលឪពុកម្ដាយរបស់យើងស្លាប់ទៅហើយ ទើបយើងគោរពគាត់នោះគឺ វាហួសពេលទៅហើយ ។ អ្នកជឿលើព្រះយេស៊ូវ ដែលមានវ័យក្មេង ហើយរស់នៅជាមួយឪពុកម្ដាយគេ ពួកគេនឹងមានសេចក្ដីប្រាថ្នាចង់ស្ដាប់បង្គាប់ឪពុកម្ដាយគេជារៀងរាល់ថ្ងៃ ។ អ្នកជឿលើព្រះយេស៊ូវ ដែលមានវ័យចាស់វិញ ហើយមានគ្រួសារផ្ទាល់ខ្លួននោះ

ពួកគេនៅតែមានចិត្តគោរពលោកទាំងពីរ និង ចេះជួយថែរក្សាលោកទាំងពីរក្នុងវ័យចាស់របស់គាត់ជានិច្ច។

បើសិនជាអ្នកជឿលើព្រះយេស៊ូវ ចង់សំដែងនូវការគោរព ចំពោះឪពុកម្តាយរបស់គាត់ ដើម្បីឱ្យបងប្អូនអ្នកភូមិមើលឃើញ ដោយធ្វើពិធីពិសេសមួយណានោះ អ្នកជឿអាចធ្វើពិធីនោះបាន តែគាត់ត្រូវធ្វើពិធីនោះតាមរបៀបដែលមិនទាក់ទងនឹងសាសនាដទៃ និង ការថ្វាយបង្គំអារក្សនោះឡើយ ។ គោលបំណងនៃពិធីនោះ គឺមិនមែនដើម្បីថ្វាយបង្គំឪពុកម្តាយ ឬទទួលផលបុណ្យសំរាប់ខ្លួន ឬសំរាប់ឪពុកម្តាយរបស់ខ្លួននោះទេ គឺដោយសារតែសំដែងនូវការគោរព និងការដឹងគុណចំពោះឪពុកម្តាយ មុនពេលគាត់ស្លាប់តែប៉ុណ្ណោះ ។



អ្នកជឿលើព្រះយេស៊ូវមិនចាំបាច់ធ្វើបុណ្យផ្សេងៗសំរាប់ខ្លួនឯងផង ថែមទាំងមិនចាំបាច់ធ្វើបុណ្យជូនឪពុកម្តាយរបស់ខ្លួន ដើម្បីទទួលសេចក្តីសុខ សេចក្តីចំរើន និងសេចក្តីសង្គ្រោះនោះទេ ។ ហេតុអ្វី ? ព្រោះព្រះគម្ពីរបានបង្រៀនច្បាស់ថា ព្រះយេស៊ូវជាព្រះពិតតែមួយ បានបន្ទាបព្រះអង្គទ្រង់ចាប់កំណើតជាមនុស្ស ហើយបានថ្វាយរូបអង្គទ្រង់ ដោយសុគតនៅលើឈើឆ្កាងសំរាប់អំពើបាបរបស់មនុស្សយើង ដើម្បីឱ្យយើងមានសេចក្តីសុខជាមួយនឹងព្រះដ៏ពិត ហើយនិងបានប្រោសឱ្យជាពីជំងឺនៃអំពើបាបផងដែរ ។ ព្រះយេស៊ូវបានធ្វើគ្រប់ទាំងបុណ្យជំនួសឱ្យយើងហើយ ដោយព្រះអង្គបានបំពេញក្រិត្យវិន័យទាំងអស់របស់ព្រះអង្គ ហើយមិនដែលធ្វើអំពើបាបណាមួយឡើយ ។ អ្នកជឿលើព្រះយេស៊ូវទុកចិត្តលើបុណ្យរបស់ទ្រង់ ព្រោះបុណ្យទាំងអស់របស់យើងគ្មានប្រយោជន៍ ចំពោះព្រះដែលល្អបរិសុទ្ធ និងសុច្ចរិតនោះឡើយ ។

ដ្បិតយើងខ្ញុំទាំងអស់គ្នាបានត្រឡប់ទៅដូចជាមនុស្សដែលមិនស្អាត ហើយអស់ទាំងអំពើសុច្ចរិតរបស់យើងខ្ញុំ ក៏ដូចជាអាវកខ្វក់ហើយ យើងខ្ញុំរាល់គ្នាស្វិតក្រៀមទៅដូចជាស្លឹកឈើ ហើយអំពើទុច្ចរិតរបស់យើងខ្ញុំ ក៏ផាត់យកយើងខ្ញុំទៅដូចជាខ្យល់ ។ (អេសាយ ៦៤:៦)